**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ: ១៧ [illegible] .០៦.អពដ

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាប់ផ្តើមអនុវត្តភ្នាក់ងារសេវាកម្មពន្ធដារ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងប្រកាសស្តីពីភ្នាក់ងារសេវាកម្មពន្ធដារលេខ ៤៥៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសេចក្តីជូនដំណឹងស្តីពីការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារលេខ ១៧២៦ អពដ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រី ដែលជាម្ចាស់សហគ្រាសជាអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក និងលោក-លោកស្រីដែលជាម្ចាស់សហគ្រាសមានសកម្មភាពជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារបានចេញអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារជូនដល់ក្រុមហ៊ុនចំនួន ៣៤ ដូចមានរាយឈ្មោះក្នុងតារាងភ្ជាប់។

ផ្អែកតាមការចេញអាជ្ញាប័ណ្ណនេះ អគ្គនាយកដ្ឋានពន្ធដារនឹងចាប់ផ្តើមអនុវត្តភ្នាក់ងារសេវាកម្មពន្ធដារ ជាលើកដំបូងចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។ ដូច្នេះ អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក និងសហគ្រាសដែលមានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវអនុវត្តដូចខាងក្រោម÷

១- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដែលមិនមែនជាភ្នាក់ងារសេវាកម្មពន្ធដារ អាចបំពេញបែបបទពន្ធដារ ដាក់លិខិតប្រកាសពន្ធ បង់ប្រាក់ពន្ធប្រចាំខែ ប្រចាំឆ្នាំ និងធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់សហគ្រាសខ្លួនផ្ទាល់។ និយោជក ឬនិយោជិតរបស់សហគ្រាសដែលមានភារកិច្ចមកបំពេញបែបបទពន្ធដារ ត្រូវពាក់ប័ណ្ណសម្គាល់ក្នុងពេលធ្វើទំនាក់ទំនងជាមួយមន្ត្រីពន្ធដារ។ ក្នុងករណីអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវការសេវាកម្មពន្ធដារត្រូវរកអ្នកផ្តល់ផ្តល់ដែលមានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ។

២- បុគ្គលទាំងឡាយដែលទទួលបានអាជ្ញាប័ណ្ណជាភ្នាក់សេវាកម្មពន្ធដារ ពីអគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិធ្វើជាអ្នកតំណាងជំនួសមុខឱ្យអ្នកជាប់ពន្ធ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធបន្ទាប់ពីទទួលបានសិទ្ធិស្របច្បាប់ជាអ្នកតំណាងពីអ្នកជាប់ពន្ធ។ ភ្នាក់ងារសេវាកម្មពន្ធដារនេះ អាចបំពេញសេវាកម្មជូនអ្នកជាប់ពន្ធ តាមរយៈបុគ្គលិករបស់ខ្លួនដោយមានលិខិតបញ្ជាក់ប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ និងត្រូវពាក់ប័ណ្ណសម្គាល់បុគ្គលិកភ្នាក់ងារសេវាកម្មពន្ធដារក្នុងពេលធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ។ អគ្គនាយកដ្ឋានពន្ធដារសូមអំពាវនាវផងដែរចំពោះលោក-លោកស្រី ឬសហគ្រាសទាំងអស់ ដែលកំពុងធ្វើឬមានបំណងធ្វើសកម្មភាពជាភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណជាភ្នាក់សេវាកម្មពន្ធដារឱ្យបានឆាប់រហ័ស។

៣- ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ បុគ្គលដែលគ្មានអាជ្ញាប័ណ្ណភ្នាក់សេវាកម្មពន្ធដារ មិនត្រូវបានអនុញ្ញាតឱ្យធ្វើទំនាក់ទំនង ឬបំពេញកាតព្វកិច្ចពន្ធដារជំនួសមុខឱ្យអ្នកជាប់ពន្ធឡើយ។

៤- ក្នុងករណី លោក-លោកស្រី ឬក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្ម ប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាប័ណ្ណ ត្រូវចាត់ទុកជាប្រព្រឹត្តអំពើរំលងស្ទះដូចមានចែងក្នុងមាត្រា ១២៨ និងត្រូវទទួលរងការផ្តន្ទាទោសតាមមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។ ដោយឡែក អ្នកជាប់ពន្ធតាមរបបពិតដែលទទួលការផ្តល់ផ្តល់សេវាកម្មពន្ធដារ ពីបុគ្គលដែលពុំមែនជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលធ្វើអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាប័ណ្ណ ត្រូវរងពិន័យជាប្រាក់ ៥ ០០០ ០០០ រៀល (ប្រាំលានរៀល)។

៥- អាជ្ញាប័ណ្ណភ្នាក់សេវាកម្មពន្ធដារទាំងអស់ដែលអគ្គនាយកដ្ឋានពន្ធដារចេញជូនក្នុងឆ្នាំ២០១៦ នឹងត្រូវចាប់ពិតសុពលភាពពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រី ដែលជាម្ចាស់សហគ្រាសជាអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក និងលោក-លោកស្រី ដែលជាម្ចាស់សហគ្រាសមានសកម្មភាពជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ពិតជាយកចិត្តទុកដាក់អនុវត្ត ចាប់ពីថ្ងៃដែលបានកំណត់ខាងលើ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ( +855 ) 23 886 708 ទូរសារ: ( +855 )23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ.........................អពដ

## តារាងបញ្ជីឈ្មោះក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

| ល.រ | ឈ្មោះសហគ្រាស | ឈ្មោះជាអក្សរឡាតាំង | TIN | លេខអាជ្ញាប័ណ្ណ |
|---|---|---|---|---|
| 1 | សារ៉េត ខេមធីស៊ី & អេ | SARETH CamTC & A Co., Ltd. | B116-901504496 | TA201606002 |
| 2 | ខេម-ហ្វីណា | CAM-FINA Co., Ltd. | K002-107040824 | TA201606003 |
| 3 | វូរី អេខោនធីង ខូ អិលធីឌី | WOORI ACCOUNTING Co., Ltd. | K003-100120962 | TA201606004 |
| 4 | ម៉ូរីសុន កាក់ & អាសូសៀរ | Morison Kak & Associes. | L001-100016134 | TA201606005 |
| 5 | សឡូម៉ុន អីខោនធីង & ខនសាល់ធីង | SOLOMON ACCOUNTING & CONSULTING Co., Ltd. | K004-107014262 | TA201606006 |
| 6 | ខេ&ធី.ហ្សេត អ៊ិនវេសម៉ិន ខូ អិលធីឌី | K&T.Z INVESTMENT Co., Ltd. | K010-901504329 | TA201606007 |
| 7 | ជា & ឡុង ព្រីមៀម សឺវីស ខូ អិលធីឌី | CHEA&LONG PREMIUM SERVICES Co., Ltd. | K010-108013316 | TA201606008 |
| 8 | អេស៊ាន ខេម អ៊ែតវ៉ាយហ្ស៊ើរី | ASIAN CAM ADVISORY Co., Ltd. | K005-901503778 | TA201606009 |
| 9 | អ៊ី ប៊ី អិម ខូ អិលធីឌី | E B M Co., Ltd. | K002-100149677 | TA201607002 |
| 10 | អេនឌ្រូ & ហ្វីលីព អីខោនធីង (អេ & ភី អីខោនធីង) | ANDREW & PHILIP ACCOUNTING Co., Ltd. (A & P ACCOUNTING) | K005-100161359 | TA201605013 |
| 11 | វ៉ាន់ដា អីខោនធីង & អឌីធីង | VANDA ACCOUNTING & AUDITING Co., Ltd. | K002-100063349 | TA201605017 |
| 12 | ខេ ភី អឹម ជី ខេមបូឌា | K P M G CAMBODIA LTD. | L001-100044654 | TA201605004 |
| 13 | ប៊ី ឌី អូ (ខេមបូឌា) | BDO (CAMBODIA) LIMITED | L001-104000708 | TA201605015 |
| 14 | ភី អេ ធី ប្រូហ្វេសិនណល លីមីធីត | P A T PROFESSIONAL LIMITED | K002-901500887 | TA201605016 |
| 15 | ឡា ប៉េ តាក់ & អីខោនធីង ខូ អិលធីឌី | LA PAIX TAX & ACCOUNTING Co., Ltd. | B116-901502727 | TA201606001 |
| 16 | ឡូរ៉ង់ ហ្វឹម លីមីធីត | LAURENT FIRM LIMITED | K005-901501123 | TA201607001 |
| 17 | អឺនស្ទ័ អែន យ៉ាំ (ខេមបូឌា) | ERNST & YOUNG (CAMBODIA) LTD. | L001-100097758 | TA201605003 |



អាគារលេខមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ផ្លូវលេខ (២៨៤) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

| | | | | |
|---|---|---|---|---|
| 18 | វីឌីប៊ី ឡូយ លីមីធីត | VDB LOI Limited | K004-106005049 | TA201605010 |
| 19 | រៀល ប៊ីហ្សនេស ខនសាល់តេសិន | REAL BUSINESS CONSULTATION Co., Ltd. | K010-901502394 | TA201605011 |
| 20 | 7 អេច ខនសាល់ធីង | 7 H CONSULTING Co., Ltd. | K009-901501683 | TA201605006 |
| 21 | អេសឌីអេសស៊ី ខនសាល់ធីង លីមីធីត | SDSC Consulting Limited | L001-901501521 | TA201605014 |
| 22 | ស៊ី.អេ.ធី.អេ.សឺវីស | C.A.T.A SERVICES | K008-901502293 | TA201605012 |
| 23 | ខេ អិម តាន & អាសូស៊ីអេត | K M TAN & ASSOCIATES Co., Ltd. | K002-100122302 | TA201605001 |
| 24 | ខេមឺរ-ហ្គោ លីមីធីត | CAMER-GO Limited | K005-105020907 | TA201605002 |
| 25 | ហ្គ្រេន ធនថុន (ខេមបូឌា) លីមីធីត | GRANT THORNTON (CAMBODIA) LIMITED | L001-104007702 | TA201605009 |
| 26 | ឌីឡយត៍ (ខេមបូឌា) ខូ អិលធីឌី | Deloitte (Cambodia) Co., Ltd. | K003-107034638 | TA201605008 |
| 27 | រ៉ូសូខូ លីមីធីត | ROSOCO LIMITED | K002-100118135 | TA201605007 |
| 28 | ហុងហ្គោ ស៊ូជី តាក់ & អ៊ីខោនធីង (ខេមបូឌា) | HONGO TSUJI TAX & ACCOUNT ING (CAMBODIA) Co., Ltd. | K002-107012685 | TA201605005 |
| 29 | អិន អេ អេស | N A S Co., Ltd. | K002-100059074 | TA201610001 |
| 30 | សុភិន អេស៊ីស៊ី | SOPHIN ACC Co., Ltd. | K007-901605017 | TA201610003 |
| 31 | ក្រូវ ហ៉រវ៉ាត (ខេអេច) អិលធីឌី | CROWE HORWATH (KH) Ltd. | K003-100158129 | TA201610002 |
| 32 | ភីភីវី ផ្លឹស ខូ អិលធីឌី | PPV PLUS CO., LTD. | K005-901637314 | TA201610004 |
| 33 | ខេ.ភី.ធី.អេស.អេស អ៊ីខោនធីង | K.P.T.S.S ACCOUNTING Co., Ltd. | K009-901503998 | TA201610005 |
| 34 | អេច អ អាយ អិន ស៊ី ធី អេ ស៊ី (ខេមបូឌា) ខូ អិលធីឌី | HRINC TAC (Cambodia) Co., Ltd. | K003-901504179 | TA201606010 |
| សរុប | 34 | | | |